# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ំ រេ ច

**មាត្រា១:** ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការ សម្បទានដីសង្គមកិច្ចថ្នាក់ជាតិដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **អ៊ឹម ឈុនលឹម** | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ជាប្រធាន |
| ២-ឯកឧត្តម | **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៣-ឯកឧត្តម | **ចាយ សាំងយុន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៤-ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម | **ហ៊ុល កន្ទុល ទេវី** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៦-ឯកឧត្តម | **ចំរុង តុងអ៊ីវ** | រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ | ជាសមាជិក |

| | | | |
|---|---|---|---|
| ៧-ឯកឧត្តម អ៊ុំ ទ្រិមាត | រដ្ឋលេខាធិការក្រសួងផែនការ | ជាសមាជិក |
| ៨-លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៩-ឯកឧត្តម ខាន់ សាវ៉ាន់ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ជាសមាជិក |
| ១០-ឯកឧត្តម ទៅ តឹន | រដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម | ជាសមាជិក |
| ១១-ឯកឧត្តម នឹម ឌុន | រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា | ជាសមាជិក |
| ១២-ឯកឧត្តម ឌុច ចនឌីតូ | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម | ជាអគ្គលេខាធិការ |

**មាត្រា ២ :** គណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ មានបេសកកម្មអនុវត្តនូវសិទ្ធិអំណាចក្នុងសមត្ថកិច្ចរបស់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខា ប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះអោយ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៣

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- ដូចមាត្រា ៤
- ឯកសារ - កាលប្បវត្តិ